ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥.០២៣.៩៥៩ ស.ជ.ណ

ថ្ងៃអង្គារ ៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកំណត់អត្រាការប្រាក់ថ្មីសម្រាប់ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី
**(Marginal Lending Facility-MLF)**

យោងតាមលិខិតលេខ ធ៥.០២១.៦៤៩ ស.ជ.ណ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យដំណើរការឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងធ្វើការផ្លាស់ប្តូរអត្រាការប្រាក់នៃឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) ពី ៤% ទៅ ៦%។

ជាមួយនឹងអត្រាការប្រាក់នៃឧបករណ៍ផ្តល់សន្ទនីភាពរយៈពេលខ្លី (MLF) ៦% ថ្មីនេះ គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចស្នើសុំធ្វើប្រតិបត្តិការបន្តដោយមិនកំណត់ ដែលនឹងអនុវត្តចាប់ពីថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ ជ្រាបជាព័ត៌មាន និងត្រៀមលក្ខណៈចូលរួមអនុវត្ត តាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព។

សូមទំនាក់ទំនង ៖
លេខទូរស័ព្ទ : (៨៥៥-២៣) ២៣០ ៦៧៥ EXT. ១០៤៨
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨
សារអេឡិចត្រូនិក : mlf_info@nbc.gov.kh
បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA